Diese Website verwendet Cookies von Google, um ihre Dienste bereitzustellen, Anzeigen zu personalisieren und Zugriffe zu analysieren. Informationen darüber, wie Sie die Website verwenden, werden an Google weitergegeben. Durch die Nutzung dieser Website erklären Sie sich damit einverstanden, dass sie Cookies verwendet. Weitere Informationen OK

# ១៩ - រឿង សួរស្តី និង អពមង្គល




Günstige STRATO Domains
STRATO DE Domain 1 Jahr 0,25€ mtl. Bis 02.08. sichern & Bares sparen!

សម័យមួយ សិរីសួស្តី និងអពមង្គល ជួបនិយាយគ្នា ។ អពមង្គលសួរទៅសិរីសួស្តីថា « លោកមានរឹទ្ធិអំណាច ដូចម្តេចខ្លះ ? » ។ សិរីសួស្តី ប្រាប់ទៅអពមង្គលថា « រឹទ្ធិអំណាចអញជាសិរីសួស្តីនេះ ខ្លាំងពូកែណាស់ សូម្បីតែមនុស្សខ្ញុំគេ ទោះគេស្អប់ គេមិនមេត្តា តែអញទៅសណ្ឋិតកាលណា នឹងបណ្តាលឲ្យគេស្នេហាទំនុកបម្រុងដរាបដល់បានរាជសម្បត្តិ » ។ ឯសិរីសួស្តី សួរទៅអពមង្គលវិញថា «រឹទ្ធិអំណាច ដូចម្តេចខ្លះ ?» ។ អពមង្គលឆ្លើយថា «រឹទ្ធិអំណាចខ្ញុំនេះ បើខ្ញុំទៅសណ្ឋិតនៅឈ្មោះណាបណ្តាលឲ្យគេស្អប់គេខឹង ខូចខាតសម្បត្តិទ្រព្យវិនាសអន្តរាយ សូម្បីតែបានរាជសម្បត្តិហើយក៏គង់ថ្លោះធ្លោយ ធ្លាក់ខ្លួនទៅជាខ្ញុំគេបាន» ។ អពមង្គលចង់ដឹងរឹទ្ធិសិរីសួស្តី ក៏ប្រាប់ថា «ខ្ញុំឃើញខ្ញុំសេដ្ឋីម្នាក់ឈ្មោះអាតុល សព្វថ្ងៃនេះ សេដ្ឋីប្រើឲ្យឃ្វាលគោក្របី សេដ្ឋីខឹងនឹងអាតុល ជេរវាយតែសព្វថ្ងៃ ថាពុំមើលថែរក្សាគោក្របី ឲ្យស្គមអស់ ខ្ញុំចង់ឲ្យលោកសិរីសួស្តីទៅសណ្ឋិតនៅលើរូបអាតុលខ្ញុំសេដ្ឋីនោះ, បើវាបានរាជសម្បត្តិខ្ញុំក៏ជឿថា លោកមានរិទ្ធិខ្លាំងពូកែប្រាកដមែន » ។ សិរីសួស្តីប្រាប់អពមង្គលវិញថា « ឯងចាំមកគន់មើលចុះ ថ្ងៃស្អែកនេះអញចូលទៅសណ្ឋិតនៅលើរូបអាតុល ខ្ញុំសេដ្ឋីហើយ, តែកាលណាអញចូលទៅនៅហើយ មិនយូរប៉ុន្មានមុខជាអាតុលខ្ញុំសេដ្ឋីនោះ វាបានសោយរាជសម្បត្តិមិនខាន » ។ លុះព្រឹកឡើង ដល់ពេលអាតុលបញ្ចេញគោក្របីពីក្រោល យកទៅឃ្វាល, សិរីសួស្តីចូលទៅសណ្ឋិតនៅលើរូបអាតុល ៗ ក៏រីករាយ សប្បាយក្នុងចិត្តប្លែកពីថ្ងៃមុន ។ ដល់ពេលល្ងាច អាតុលកៀងគោក្របី ត្រឡប់មកបញ្ចូលក្រោលឯផ្ទះវិញ ។ សេដ្ឋីទាំងប្តីប្រពន្ធឈរមើលគោក្របី ឃើញអាតុលរាំងទ្វារក្រោលគោក្របីខ្ទាប់ហើយ ទើបឡើងទៅអង្គុយលើផ្ទះសេដ្ឋីជាចៅហ្វាយ នៅត្រង់កន្លែងខ្លួន ដូចសព្វដង ។ កាលសេដ្ឋីទាំងប្តីប្រពន្ធ ឃើញអាតុលហើយ ក៏នឹកក្នុងចិត្តអាណិតថា «ឱអាតុលអើយ ! ទៅឃ្វាលគោក្របី អត់បាយក្រហាយទឹកទាល់ល្ងាច ទើបបានបាយបរិភោគ ម្ល៉េះសមវាឃ្លានយ៉ាងណាទៅ ? គិតហើយ ក៏ដាស់តឿនខ្ញុំកំដរស្រីៗ ឲ្យដោះដួសបាយស៊ីរាល់គ្នា ។ខ្ញុំស្រីៗក៏ដោះដួសភោជនាហារណា ដែលមានឱជារសយកទៅដាក់ជូនសេដ្ឋី ហើយប្រជុំគ្នាបរិភោគ ។ សេដ្ឋីប្តីប្រពន្ធ ហៅអាតុលឲ្យមកជិត ចាប់ម្ហូបដែលមានឱជារសឲ្យបរិភោគ ៗរួច សេដ្ឋីប្តីប្រពន្ធគន់មើលកិរិយាឫករូបអាតុលនោះ ក៏ឃើញថាសមរម្យឥតខ្ចោះ រកទាស់ចិត្តត្រង់ណាគ្មាន ។ បណ្តាជនទាំងស្រីប្រុស ឲ្យតែឃើញរូបអាតុលនោះកាលណា ក៏មានចិត្តស្នេហាមេត្តាពន់ប្រមាណ ។ ឯសេដ្ឋីប្តីប្រពន្ធជាចៅហ្វាយអាតុលនោះ និយាយគិតគ្នាថា « សព្វថ្ងៃនេះ យើងឥតកូន, ទ្រព្យសម្បត្តិក៏មានច្រើន, អំណើះតទៅបើឥតពីយើង ទ្រព្យសម្បត្តិនឹងអន្តរាយអសារឥតការ, គួរលើកអាតុលឡើងតម្កើងធ្វើជាកូន កុំឲ្យវាឃ្វាលគោក្របីទៀត ត្បិតអាតុលនេះ សាច់ឈាមឫកពាល្អណាស់ល្មមសមគួរជាកូនយើងបាន » ។ ដល់ពេលល្ងាច អាតុលត្រឡប់មកពីឃ្វាលគោក្របីវិញ សេដ្ឋីទាំងប្តីប្រពន្ធ ឃើញអាតុលរឹតតែស្នេហាមេត្តាពន់ពេក ក៏ហៅឲ្យបរិភោគបាយជាមួយមិនឃ្លាតឆ្ងាយពីខ្លួន ឈប់ឲ្យឃ្វាលគោក្របី ចាប់តាំងពីថ្ងៃនោះតទៅ ។ សេដ្ឋីទាំងប្តីប្រពន្ធ យកសំលៀកបំពាក់ គ្រឿងមាសប្រាក់មកតុបតែងឲ្យអាតុលហើយប្រាប់ថា «ពីថ្ងៃនេះទៅ អញទុកឯងជាកូន, អំណើះពីអញទៅ ទ្រព្យសម្បត្តិអញទាំងប៉ុន្មាន នៅលើដៃកូនឯងទាំងអស់ » ។ អាតុលក៏រីករាយសប្បាយជាទីបំផុត ។ ដោយអំណាចសិរីសួស្តី សណ្ឋិតលើខ្លួន លុះអាតុលចំរើនអាយុពេញរូបរាងឡើង ក៏រឹតតែល្អ រកបុរសឯណានឹងប្រៀបផ្ទឹមស្មើពុំបាន ។

រាល់ព្រឹកល្ងាច សេដ្ឋីតែងចូលគាល់ព្រះមហាក្សត្រ ពុំដែលលស់ខាន ក៏នាំយកអាតុលជាកូនទៅគាល់ផង ។ ព្រះរាជាទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គ ស្តេចចេញប្រថាប់នៅក្រឡាព្រះនៅឆ្វល់ ព្រះរាជបុត្រី ក៏ជិតដោយក្រោយព្រះអង្គមក ។ កាលមហាសេដ្ឋីនាំកូនចូលក្រាបបង្គំគាល់ព្រះមហាក្សត្រ ទ្រង់ឆ្មៀងព្រះនេត្រ ឃើញសេដ្ឋីនិងកូនអង្គុយគាល់ទន្ទឹមគ្នា ទ្រង់ត្រាស់សួរថា « កូនសេដ្ឋីឬ ? សេដ្ឋីទូលថា « កូនទូលព្រះបង្គំជាខ្ញុំ » ។ ស្តេចទ្រង់សរសើរថា « កូនសេដ្ឋីមានរូបមានឫកល្អណាស់ »។ ព្រះរាជបុត្រីក៏នឹកក្នុងព្រះទ័យថា « កូនសេដ្ឋីនោះមានលំអនឹងរកបុរសណាផ្ទឹមពុំបាន ធ្វើម្តេចនឹងបានជាស្វាមីអញ ? ដល់ពេលគួរ ស្តេចនិងព្រះរាជបុត្រីនោះ យាងចូលទៅខាងក្នុងវិញ, សេដ្ឋីក្រាបថ្វាយបង្គំលា នាំកូនត្រឡប់មកផ្ទះ, ដល់ផ្ទះកូននិយាយនឹងសេដ្ឋីថា «សូមលោកឪលោកម៉ែមេត្តាកូន ទៅដណ្តឹងព្រះរាជបុត្រីស្តេចឲ្យខ្ញុំ ត្បិតកាលខ្ញុំចូលទៅគាល់ជាមួយលោកឪពុកនោះ, ខ្ញុំបាទឃើញច្បាស់ព្រះរាជបុត្រីនោះល្អណាស់ បើមិនដណ្តឹងឲ្យខ្ញុំទេ ខ្ញុំមុខជាស្លាប់មិនខាន» ។ ដោយស្នេហាកូនពេក សេដ្ឋីប្តីប្រពន្ធក៏ប្រថុយខ្លួនរៀបតុមាសប្រាក់ ដាក់គ្រឿងបណ្ណាការជាតង្វាយសុទ្ធតែពេជ្រនិងមាសពោរពាសច្រើនតុ, លុះព្រឹកឡើងនាំតង្វាយនោះទៅរៀបចំក្នុងទីព្រះរាជរោង ។ ព្រះមហាក្សត្រ ស្តេចចេញមកឲ្យនាហ្មឺនធំតូចគាល់ ។ សេដ្ឋីទាំងប្តីប្រពន្ធ ក៏គាល់នៅជិតគ្រឿងបណ្ណាការតង្វាយនោះ ។ ស្តេចត្រាស់សួរថា « សេដ្ឋី ! តង្វាយនេះ ប្លែកណាស់ មានការអ្វី ? » ។ សេដ្ឋីប្តីប្រពន្ធក្រាបបង្គំទូលថា « សូមព្រះរាជតេជះតម្កល់លើត្បូង សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ សូមទ្រង់ប្រោសព្រះរាជទានព្រះរាជបុត្រី ផ្សំនឹងកូនទូលព្រះបង្គំជាខ្ញុំ » ។ ស្តេចទ្រង់ជ្រាប ទ្រង់ព្រះរាជអនុញ្ញាត ទ្រង់ចាត់មុខក្រសួង ឲ្យរៀបព្រះរាជពិធីសមោសរ, ហោរាថ្វាយឫក្សទ្រង់ផ្សំព្រះរាជបុត្រីនឹងកូនសេដ្ឋី ហើយផ្ទេរទាំងរាជសម្បត្តិឲ្យគ្រប់គ្រងផង ។ លុះបានរាជសម្បត្តិហើយ ស្តេចតុលនិងព្រះនាងមហេសី ក៏បានប្រកបសេចក្តីសុខឥតទុក្ខា មហាប្រសើររៀងទៅ ។ និយាយពីរឿងអពមង្គលវិញ កាលជួបនឹងសិរីសួស្តីក៏ថា «លោកសិរីសួស្តីខ្ញុំជឿហើយឃើញថា លោកមានរឹទ្ធិ ជួយស្តេចតុលឲ្យបានរាជសម្បត្តិមែន, ដូច្នេះលោកចាំមើលរឹទ្ធិខ្ញុំវិញម្តង សូមលោកលែងសណ្ឋិតនៅលើរូបស្តេចតុលទៅ » ។ សិរីសួស្តីក៏ថយចេញពីរូបស្តេចតុល, អពមង្គលក៏ចូលទៅសណ្ឋិតលើរូបស្តេចតុលម្តង ។ ឯស្តេចតុលចេះតែមួម៉ៅ ក្តៅក្រហាយ, ព្រះនាងមហេសីស្រីបរិវារ ក៏ពុំសូវយកចិត្តទុកដាក់គោរពប្រណិប័តន៍ បណ្តាលចិត្តឲ្យតែខឹងស្អប់ស្តេចតុល អស់លោកចតុស្តម្ភទាំងប៉ុន្មាន ៗ ក៏ពុំសូវចូលចិត្តគិតចង់ឲ្យតែព្រះវររាជបិតាក្មេក យករាជ្យសម្បត្តិទៅវិញ ។ ចំណែកស្តេចតុល ចេះតែក្តៅក្រហាយអន្ទះអន្ទែង ចង់ទៅក្រសាលទីទំនាបមាត់បឹងក្រែពេក ក៏នាំព្រះនាងមហេសី ស្រីបរិវារចេញទៅ, លុះទៅដល់ក៏ឲ្យធ្វើព្រះពន្លាស្នាក់ក្រសាល ។ នៅទីមាត់បឹងនោះ ឮតែសព្ទសូរត្រដោកគោ ត្រដោកក្របី, ស្តេចតុលក៏ភ្ញាកនឹកអាណិតខ្លួនកាលនៅជាខ្ញុំមហាសេដ្ឋី ដែលគេប្រើឲ្យឃ្វាលក្របី ហើយក៏ទ្រង់ព្រះកន្សែងខ្សឹកខ្សួល ។ ព្រះនាងមហេសីសួរថា «ព្រះអង្គ ! ហេតុអ្វីក៏ទ្រង់ខ្សឹកខ្សួលម្ល៉េះ ?»។ ស្តេចតុលប្រាប់ព្រះនាងមហេសីតាមត្រង់ថា «លាក់បាំងអី ម្ចាស់អូនអើយ ! ខ្លួនបងនេះ មិនមែនកូនសេដ្ឋីទេ, ពីដើមបងជាខ្ញុំសេដ្ឋី ៗ គេប្រើឲ្យឃ្វាលគោក្របី ឥឡូវឮត្រដោកក្របីគោ បងនឹកស្រងេះស្រងោចអាណិតខ្លួន បានជាបងយំ » ។ ព្រះនាងមហេសីបានឮថាជាខ្ញុំសេដ្ឋី ក៏មានចិត្តទោមនស្សក្នុងព្រះទ័យពន់ពេកថា « ឱព្រះវរបិតា ពុំគួរផ្សំផ្គុំកូន ផ្ទេរទាំងរាជសម្បត្តិឲ្យទៅខ្ញុំគេសោះ » ខ្វាល់ហើយក៏នាំស្តេចតុលនឹងស្រីបរិវារ ដែលតាមហែទៅទាំងប៉ុន្មាន ត្រឡប់ចូលព្រះរាជវាំងវិញ ចូលក្រាបទូលវររាជបិតាមាតា តាមរឿងដែលស្តេចតុលយំគ្រប់ប្រការ ។ ស្តេចជាព្រះវររាជបិតាមាតាទ្រង់ជ្រាបហើយ ទ្រង់ក្រោធពន់ប្រមាណ ទ្រង់ត្រាស់ឲ្យហៅសេដ្ឋីទាំងប្តីប្រពន្ធមកដៀលត្មះជាទម្ងន់ ហើយប្រគល់ស្តេចតុល ឲ្យទៅសេដ្ឋីប្តីប្រពន្ធ នាំយកទៅផ្ទះវិញ ។ ឯរាជសម្បត្តិ ស្តេចទ្រង់គ្រប់គ្រងវិញ ។ សេដ្ឋីប្តីប្រពន្ធនាំអាតុលទៅដល់ផ្ទះហើយជេរវាយ ត្មះតិះដៀល លែងរាប់អានជាកូន ឲ្យអាតុលឃ្វាលគោក្របីទុកជាខ្ញុំដូចដើម ។

> ***មារយាទថ្លៃឲ្យយក មារយាទថោកឲ្យរៀរ***

កម្ពុជសុរិយាលេខ ១- ២ -៣ ឆ្នាំ ១៩៣៣ – ៤ ទំព័រ ១៦២ រៀបរៀងដោយព្រះអគ្គលេខាណុប នៅក្រុមព្រះរាជនិពន្ធ ។

g+1 +1 Recommend this on Google

Tablet Angebote

Tablets mit o2 Go Flat wählen & 240€ sparen. Jetzt mobil bestellen.

ចង់បាននូវរឿងព្រេងថ្មីៗទេ? សូមសរសេរអីមែលក្នុងប្រអប់នេះ

Email address...

ចង់បាន

នាំមកជូនលោកអ្នកដោយ

